ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 05-Oct-2015, 09:08
CMS/CFO: Sann Rada

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour supreme

សំណុំរឿងលេខ: ០០២/១៩-កញ្ញា-២០០៧/អ.វ.ត.ក/អ.ជ.ត.ក
Case File/Dossier N°. 002/19-09-2007/ECCC/SC

**នៅចំពោះមុខ៖**

**ចៅក្រម គង់ ស្រ៊ីម ប្រធាន**
**ចៅក្រម Chandra Nihal JAYASINGHE**
**ចៅក្រម សោម សិរីវឌ្ឍ**
**ចៅក្រម Agniezska KLONOWIECKAMILART**
**ចៅក្រម ម៉ុង មុន្នីចរិយា**
**ចៅក្រម Florence Ndepele Mwachande MUMBA**
**ចៅក្រម យ៉ា ណារិន**

**កាលបរិច្ឆេទឯកសារ៖** ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០១៥
**ភាសាដើម៖** ខ្មែរ/អង់គ្លេស
**ចំណាត់ថ្នាក់ឯកសារ៖** សាធារណៈ

# សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំបន្ថែមចំនួនទំព័រសម្រាប់ដាក់សារណាតបទៅនឹងសំណើទីប្រាំមួយរបស់ នួន ជា សុំដាក់ភស្តុតាងបន្ថែម

**សហព្រះរាជអាជ្ញា** **សហមេធាវីជនជាប់ចោទ នួន ជា**

ជា លាង
Nicholas KOUMJIAN

**<u>ជនជាប់ចោទ</u>**

ខៀវ សំផន

នួន ជា

**<u>សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី</u>**

ពេជ អង្គ
Marie GUIRAUD

សុន អរុណ
Victor KOPPE

**<u>សហមេធាវីជនជាប់ចោទ ខៀវ សំផន</u>**

គង់ សំអុន

Anta GUISSÉ
Arthur VERCKEN

**អង្គជំនុំជម្រះតុលាការកំពូល**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យនៅចន្លោះពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩ (“**អង្គជំនុំជម្រះតុលាការកំពូល**” និង“**អ.វ.ត.ក**”)

**បានទទួល**“សំណើរបស់សហព្រះរាជអាជ្ញា សុំបន្ថែមចំនួនទំព័រ និងដាក់សារណាតបតែមួយភាសាទៅនឹងសំណើទីប្រាំមួយសុំដាក់ភស្តុតាងបន្ថែមរបស់ នួន ជា” (“សំណើសុំ”)[1],

**កត់សម្គាល់ឃើញ**ថា សហព្រះរាជអាជ្ញា បង្ហាញថា ខ្លួនមានបំណងដាក់សារណាតបទៅនឹងសំណើទីប្រាំមួយសុំដាក់ភស្តុតាងបន្ថែមរបស់ នួន ជា[2] និងស្នើសុំការអនុញ្ញាតពីអង្គជំនុំជម្រះតុលាការកំពូលបន្ថែមទំព័រចំនួន ១៥ ទំព័រទៀត ដែលលើសពីការកំណត់ចំនួនទំព័រ ត្រឹមតែ ៣០ ទំព័រ តាមមាត្រា ៥.២ នៃសេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសារ[3] ដោយបានលើកឡើងថា “កាលៈទេសៈពិសេស” តម្រូវឱ្យអនុវត្តតាមមាត្រា ៥.៤ នៃសេចក្ដីណែនាំស្ដីពីការដាក់ឯកសារ[4],

**កត់សម្គាល់ឃើញ**ថា ក្នុងការគាំទ្រនូវការលើកឡើងរបស់ខ្លួន សហព្រះរាជអាជ្ញា បានកត់សម្គាល់ថា នួន ជា ត្រូវបានអនុញ្ញាត ទាក់ទងនឹងសំណើទីប្រាំមួយសុំដាក់ភស្តុតាងបន្ថែមរបស់គាត់ ឱ្យបន្ថែមចំនួនទំព័រដែលលើសពីការកំណត់តាមការអនុវត្តធម្មតា ដល់ទៅពីរដង និងថា នួន ជា ប្រកាសថា សំណើរបស់គាត់ “ចង្អៀតណែនខ្លាំងណាស់” និងបណ្ដាលមកពីការច្របាច់បញ្ចូលគ្នានូវសំណើសុំដាក់ភស្តុតាងបន្ថែមដាច់ដោយឡែកពីគ្នាចំនួនបី[5] និងថា សហព្រះរាអាជ្ញាលើកឡើងថា សំណើសុំបន្ថែមទំព័រនេះ ដែលសុំ“ត្រឹមតែ

---

[1] ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារលេខ F2/8/2។

[2] សំណើទីប្រាំមួយរបស់ នួន ជា សុំពិចារណា និងទទួលយកភស្តុតាងបន្ថែមទាក់ទងនឹងបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១ ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារលេខ F2/8 (“សំណើទីប្រាំមួយសុំដាក់ភស្តុតាងបន្ថែម”)។

[3] សេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក, ECCC/01/2007/វិ.ទី៨ ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០១២ (“សេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសារ”)។

[4] សំណើសុំ កថាខណ្ឌ ១, ៣ និង ៤។ សំណើរបស់សហព្រះរាជអាជ្ញាសុំដាក់សារណាតបរបស់ខ្លួនដែលរំពឹងថានឹងដាក់តែមួយភាសាប៉ុណ្ណោះ (សំណើកថាខណ្ឌ ១, ២ និង ៤) ក្រោយមក ត្រូវបានដកចេញវិញៈ អ៊ីមែលអេឡិចត្រូនិកផ្ញើពីការិយាល័យរបស់សហព្រះរាជអាជ្ញាមកកាន់ក្រឡាបញ្ជីនៃអង្គជំនុំជម្រះតុលាការកំពូលថា“កែប្រែទៅជាឯកសារលេខ F2/8/2” នៅថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១៥ នៅម៉ោង ៣ និង ៣នាទីល្ងាច ដាក់នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល។

[5] Request, para. 3.

ពាក់កណ្ដាលនៃចំនួនកំណត់ប៉ុណ្ណោះ” តិចជាងចំនួនទំព័រ ដែលបានអនុញ្ញាតពេលនោះលើសំណើទីប្រាំមួយ របស់ នួន ជា សុំដាក់ភស្តុតាងបន្ថែម គឺជាការចាំបាច់ក្នុងការរៀបចំសារណាតបឱ្យមានសំអាងហេតុ សមស្រប“បើធៀបទៅនឹងវិសាលភាព”នៃសំណើសុំរបស់ នួន ជា[6],

**រំលឹក**ថា អង្គជំនុំជម្រះតុលាការកំពូលសម្រេចកាត់បន្ថយការកំណត់កាលបរិច្ឆេទសម្រាប់ដាក់សារណាតប ទៅនឹងសំណើ[7] និងថា ពុំទទួលយកសារណាតបណាមួយ នៅក្នុងការកំណត់កាលបរិច្ឆេទដែលបានកែប្រែ នេះឡើយ,

**រំលឹក**ថា មាត្រា ៥.២ នៃសេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសារ កម្រិតត្រឹមតែ ៣០ ទំព័រប៉ុណ្ណោះ ជាភាសាអង់គ្លេស ឬបារាំង នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល លើកលែងតែមានការចែងផ្ទុយពីនេះ,

**រំលឹក**ថា មាត្រា ៥.៤ នៃសេចក្ដីណែនាំងអនុវត្តស្ដីពីការដាក់ឯកសារ អនុញ្ញាតឱ្យអង្គជំនុំជម្រះពាក់ព័ន្ធបន្ថែមចំនួនទំព័រ ដោយអាស្រ័យលើភាគីស្នើសុំនោះ បង្ហាញពីអត្ថិភាពនៃកាលៈទេសៈពិសេស,

**ពិចារណាឃើញ** ថា ការកំណត់ចំនួនទំព័រ “បើទោះបីជាសំខាន់យ៉ាងណាក៏ដោយ ត្រូវតែកែប្រែឱ្យស្រប ទៅតាមតម្រូវការចាំបាច់របស់ភាគី ដើម្បីឱ្យមានតុល្យភាពសមស្របទៅតាមគោលការណ៍សំខាន់ៗនៃ ប្រសិទ្ធិភាពរបស់តុលាការ”[8] និងថា ក្នុងន័យនេះ ភាគីដែលស្នើសុំ ត្រូវបង្ហាញ“មូលហេតុត្រឹមត្រូវ” ដោយបានលើកឡើងនូវ “អត្ថប្រយោជន៍ផ្នែកច្បាប់ជាក់លាក់” ដែលចាំបាច់តម្រូវឱ្យមានការបន្ថែមចំនួនទំព័រដែលស្នើសុំនោះ;[9]

**ពិចារណាឃើញ**ថា សេចក្ដីសម្រេចពីមុនលើសំណើសុំបន្ថែមពេលវេលា និងទំព័រ បានទទួលយកវិសាល ភាព និងភាពស្មុគស្មាញ ក្នុងការដាក់ឯកសារខាងមុខរបស់ភាគី ដែលស្នើសុំថាជាមូលហេតុត្រឹមត្រូវដោយ បំពេញទៅតាមលក្ខខណ្ឌនៃមាត្រា ៥.៤ នៃសេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសារ ដោយបានបញ្ជាក់ថា

---

[6] សំណើសុំ កថាខណ្ឌ ៣។

[7] សេចក្ដីសម្រេចអនុលោមតាមវិធាន ៣៩(២) នៃវិធានផ្ទៃក្នុង ថ្ងៃទី ១ ខែ តុលា ឆ្នាំ ២០១៥ ឯកសារលេខ F2/8/3។

[8] សេចក្ដីសម្រេចលើសំណើរបស់មេធាវីការពារក្ដីសុំបន្ថែមចំនួនទំព័រ និងពេលវេលាសម្រាប់ឆ្លើយតប ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារលេខ F13/2 (“សេចក្ដីសម្រេចលើកទីពីរស្ដីពីការបន្ថែមទំព័រ និងពេលវេលា”) កថាខណ្ឌ ១៥។

[9] សេចក្ដីសម្រេចលើសំណើសុំរបស់មេធាវីការពារក្ដីសុំបន្ថែមពេលវេលា និទំព័រ លើសេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ និងសារណា ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៤ ឯកសារលេខ F3/3 (“សេចក្ដីសម្រេចបន្ថែមពេលវេលា និងទំព័រ”) កថាខណ្ឌ ១០។

ការគ្រាន់តែផ្អែកទៅលើសំណើរបស់ភាគីដើម្បីឱ្យមានប្រសិទ្ធិភាពដូចគ្នានោះ គឺពុំសមស្រប ដោយសារចំណុចនេះតែមួយ ពុំបានបង្ហាញនូវ "អត្ថប្រយោជន៍ផ្អែកច្បាប់ជាក់លាក់" ដែលគាំទ្រការទាមទាររបស់ភាគីដែលស្នើសុំឡើយ[10],

**ពិចារណាឃើញ**ថា ក្នុងរឿងក្តីបច្ចុប្បន្នេះ បើទោះបីជាមានការបញ្ជាក់ច្បាស់លាស់នៅក្នុងការយល់ឃើញរបស់អង្គជំនុំជម្រះតុលាការកំពូលលើបញ្ហានេះក៏ដោយ ក៏សហព្រះរាជអាជ្ញានៅតែទទូចធ្វើយុត្តិកម្មទៅលើដំណោះស្រាយដែលបានស្នើឡើង ដោយធ្វើការយោងទៅលើសំណើរបស់ភាគីដទៃទៀតដែលបានសុំបន្ថែមចំនួនទំព័រ និងលទ្ធផលដែលទទួលបាន ដោយសារបានបង្ហាញពីអត្ថិភាពនៃ"កាលៈទេសៈពិសេស"តាមមាត្រា ៥.៤ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ ដែល នួន ជា ជឿជាក់ថា ជាចំណុចសំខាន់ក្នុងការដាក់ឯកសាររបស់ខ្លួន ដោយពុំចាំបាច់លើកឡើងពីបញ្ហានៃ"ទំហំ" និងភាពស្មុគស្មាញ[11] ដែល ពិតបាកដណាស់ គឺជាភាពចំបាច់ដែលតម្រូវឱ្យអង្គជំនុំជម្រះជឿជាក់បានថា សំណើនេះ មានមូលដ្ឋានត្រឹមត្រូវ,

**ពិចារណាឃើញ**ថា បើទោះជាមានមូលដ្ឋានពុំសូវល្អក៏ដោយ ក៏ប៉ុន្តែ តាមការយល់ឃើញរបស់អង្គជំនុំជម្រះតុលាការកំពូល សំណើសុំនេះ មានលក្ខណៈសមហេតុផល តាមការសន្មតថា សហព្រះរាជអាជ្ញាមានបំណង"ឆ្លើយតបយ៉ាងសមស្រប"[12] ទៅនឹងភាពអាចទទួលយកបាននៃភស្តុតាងនីមួយៗដែលបានស្នើឡើង និងភាពជឿជាក់បាន និងភាពជាប់ពាក់ព័ន្ធនៃការលើកឡើងយ៉ាងវែងអន្លាយអំពីប្រវត្តិនៃកាលៈទេសៈដែល នួន ជា ចាត់ទុកថាជា "ដើមចម និងផលវិបាក""នៃព្រឹត្តិការណ៍ដែលបានកើតឡើងក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ" ដែលគ្រាន់តែចំណុចនេះ អាចត្រូវការជិត ៣០ ទំព័រឯណោះ,[13]

---

[10] សេចក្តីសម្រេចលើសំណើសុំបន្ថែមបន្ថែមពេលវេលា និងចំនួន ទំព័រសម្រាប់សារណាបណ្តឹងសាទុក្ខ និងសារណាតប ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤ ឯកសារលេខ F9 កថាខណ្ឌ ១៤។ សេចក្តីសម្រេចបន្ថែមពេលវេលា និងទំព័រ កថាខណ្ឌ ១០។ សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា សុំបន្ថែមចំនួនទំព័រ និងពេលវេលា ដើម្បីឆ្លើយតបទៅនឹងបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១ ថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ F23/1 កថាខណ្ឌ ៩។ *សូមមើលផងដែរ* សេចក្តីសម្រេចទីពីរស្តីពីការបន្ថែមពេលវេលា និងទំព័រ កថាខណ្ឌ ១១។

[11] សំណើសុំ កថាខណ្ឌ ៣។

[12] សំណើសុំ កថាខណ្ឌ ៣។

[13] សំណើសុំដាក់ភស្តុតាងបន្ថែមលើកទីប្រាំមួយកថាខណ្ឌ ១៧។

សំណុំរឿងលេខ: ០០២/១៩-កញ្ញា-២០០៧/អ.វ.ត.ក/អ.ជ.ត.ក

ឯកសារលេខ F2/8/2/1

## អាស្រ័យហេតុនេះសម្រេច÷

**ទទួលយក**សំណើនេះ,

**អនុញ្ញាត**ឱ្យសហព្រះរាជអាជ្ញា ដាក់សារណាតបរបស់ខ្លួនជាសរុប ៤៥ ទំព័រ ទៅនឹងសំណើទីប្រាំមួយរបស់ នួន ជា សុំដាក់ភស្តុតាងបន្ថែម ជាភាសាអង់គ្លេស ឬបារាំង ដោយសមមូលជាមួយនឹងភាសាខ្មែរ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០១៥

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

E.C.C.C * C.E.T.C

**គង់ ស្រ៊ឹម**